ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៩៥ ព.ណ.ឋល.ប្រក

# ប្រកាស
# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់
# នាយកដ្ឋានកិច្ចការពិព័រណ៍

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** :

នាយកដ្ឋានកិច្ចការពិព័រណ៍ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម មានមុខងារ និងភារកិច្ចដូចតទៅ៖

- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ព្រមទាំងធ្វើការណែនាំ និងលើកទឹកចិត្តដល់ការចូលរួមរបស់ផលិតករ និងអាជីវករជាតិ នៅក្នុងកម្មវិធីពិព័រណ៍ក្រៅប្រទេស
- គ្រប់គ្រងមជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មជាតិ ខេត្ត ក្រុង និងតំបន់
- សម្របសម្រួល លើកទឹកចិត្ត គ្រប់គ្រង និងចេញលិខិតអនុញ្ញាតដល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ដែលរៀបចំដោយក្រុមហ៊ុនក្នុងប្រទេសក្រុមហ៊ុន



ម្តុំលេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Phone/Facsimile: (855)-23 866 469

បរទេស និងស្ថាប័ននានា

- ទទួលបន្ទុកជាចំណុចប្រសព្វ សម្រាប់ការងារការិយាល័យពិព័រណ៍អន្តរជាតិ (BIE) និងការងារជាលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំចូលរួមពិព័រណ៍ពិភពលោកនិងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**ប្រការ ២** :

នាយកដ្ឋានកិច្ចការពិព័រណ៍ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៣** :

នាយកដ្ឋានកិច្ចការពិព័រណ៍ មានការិយាល័យចំណុះចំនួន ០៤គឺ៖

១- ការិយាល័យកិច្ចការពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស

២- ការិយាល័យកិច្ចការពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេស

៣- ការិយាល័យកិច្ចការពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ និងពិភពលោក

៤- ការិយាល័យគ្រប់គ្រងព្រឹត្តិការណ៍ពាណិជ្ជកម្ម

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៤** :

ការិយាល័យកិច្ចការពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស មានភារកិច្ច៖

- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស
- ធ្វើការណែនាំ និងលើកទឹកចិត្តដល់ការចូលរួមរបស់ផលិតករ និងអាជីវករជាតិ នៅក្នុងកម្មវិធីពិព័រណ៍ក្នុងប្រទេស
- គ្រប់គ្រង និងចេញលិខិតអនុញ្ញាតដល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស ដែលរៀបចំដោយក្រុមហ៊ុនក្នុងប្រទេស ក្រុមហ៊ុនបរទេស និងស្ថាប័ននានា
- សម្របសម្រួល លើកទឹកចិត្ត ដល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស ដែលរៀបចំដោយក្រុមហ៊ុនក្នុងប្រទេស ក្រុមហ៊ុនបរទេស និងស្ថាប័ននានា
- រៀបចំផែនការ និងកម្មវិធីសម្រាប់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៥** :

ការិយាល័យកិច្ចការពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេស មានភារកិច្ច៖

- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេស
- ធ្វើការណែនាំ និងលើកទឹកចិត្តដល់ការចូលរួមរបស់ផលិតករ និងអាជីវករជាតិ នៅក្នុងកម្មវិធីពិព័រណ៍ក្រៅប្រទេស
- សម្របសម្រួល និងរៀបចំបែបបទសម្រាប់ការចូលរួមរបស់ផលិតករ និងអាជីវករជាតិ នៅក្នុងកម្មវិធីពិព័រណ៍ក្រៅប្រទេស

- រៀបចំផែនការ និងកម្មវិធីសម្រាប់កម្ពុជា ចូលរួមពិព័រណ៍ពាណិជ្ជកម្មនៅក្រៅប្រទេស
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៦** :

ការិយាល័យកិច្ចការពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ និងពិភពលោក មានភារកិច្ចៈ

- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ (ដែលមានលក្ខណៈជាអន្តរក្រសួង ហើយ មានរៀបចំពន្លាជាតិ សម្រាប់តំណាងប្រទេស)
- រៀបចំ និងចូលរួមពិព័រណ៍ពិភពលោក
- ទទួលបន្ទុកជាចំណុចប្រសព្វ សម្រាប់ការងារការិយាល័យពិព័រណ៍អន្តរជាតិ (BIE)
- ជាលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៧** :

ការិយាល័យគ្រប់គ្រងព្រឹត្តិការណ៍ពាណិជ្ជកម្ម មានភារកិច្ចៈ

- គ្រប់គ្រង និងតាមដានរាល់សកម្មភាពនៃការរៀបចំពិព័រណ៍ពាណិជ្ជកម្មទាំងឡាយនៅកម្ពុជា
- គ្រប់គ្រង និងតាមដាននូវរាល់ព្រឹត្តិការណ៍ពាណិជ្ជកម្មទាំងឡាយដែលបានប្រព្រឹត្ត និងរៀបចំនៅកម្ពុជា
- ត្រួតពិនិត្យ និងវាយតម្លៃនូវរាល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មនៅកម្ពុជា ដើម្បីប្រមូលចំណូលជូនរដ្ឋតាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម និងប្រកាសអន្តរក្រសួង
- គ្រប់គ្រង និងចាត់ចែងនូវការងាររដ្ឋបាលទូទៅរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៨** :

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៩** :

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៩
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធនាយកដ្ឋានកិច្ចការពិព័រណ៍

